ភ្នំពេញ , ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៣

# សេចក្តីសំរេចលេខ ០៦ សសរ ស្តីពីការផ្ទេរអាគាររបស់ នាយកដ្ឋានបណ្តុះបណ្តាលនគរបាល ជូនក្រសួងកិច្ចការ នារីយុវជន និង កីឡា ដើម្បីធ្វើទីស្តីការក្រសួង

****

រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា

****

- បានឃើញក្រឹត្យចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ របស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋកម្ពុជា ស្តីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា
- យោងតាមសំណូមពរចាំបាច់

**សំរេច**

ប្រការ ១ : ផ្ទេរអាគាររបស់នាយកដ្ឋានបណ្តុះបណ្តាលនគរបាលរបស់ក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ ដែលស្ថិតក្នុងបរិវេណ បូរីកីឡា ជូនទៅក្រសួងកិច្ចការនារី យុវជន និង កីឡា ដើម្បីធ្វើទីស្តីការក្រសួង ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ និង រដ្ឋមន្ត្រីក្រសួងកិច្ចការនារី យុវជន និង កីឡា មានភារកិច្ចអនុវត្តសេចក្តីសំរេច នេះ ។

**តប. សហប្រធាន**

នៃរដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា

**ឧបនាយករដ្ឋមន្ត្រី**

ហត្ថលេខា

**គាត ឈន**